**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខ :..៧៦៤..៣៥.១១ ប.ស្ក

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពន្យាកាលបរិច្ឆេទ ការផ្លាស់ប្តូរមណ្ឌលប្រឡង និងការបញ្ជាក់បន្ថែម នូវលក្ខខណ្ឌប្រឡងជ្រើសរើសនិស្សិត ចូលបម្រើការងារជាមន្ត្រីរាជការ ក្នុងក្របខ័ណ្ឌក្រសួងបរិស្ថានសម្រាប់ឆ្នាំ២០១៤

ក្រសួងបរិស្ថាន មានកិត្តិយសសូមជូនដំណឹងដល់និស្សិត និងសាធារណៈជនដែលបាន ឬមានបំណងដាក់ពាក្យសុំប្រឡងជ្រើសរើសចូលបម្រើការងារជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួងបរិស្ថាន សម្រាប់ឆ្នាំ២០១៤ ឱ្យបានជ្រាបថា៖ ដើម្បីបង្កើនការចូលរួមប្រឡងប្រជែងឱ្យកាន់តែមានសភាពទូលំទូលាយថែមទៀត **ក្រសួងសម្រេចពន្យាកាលបរិច្ឆេទប្រឡងជ្រើសរើស និងបញ្ជាក់បន្ថែមនូវលក្ខខណ្ឌមួយចំនួនដូចបានកំណត់ក្នុងសេចក្តីជូនដំណឹងលេខ ២១២ សជណ ប.ស្ក. ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤** ដែលមានខ្លឹមសារលម្អិតដូចខាងក្រោម៖

### ១. <u>សេចក្តីបញ្ជាក់បន្ថែមលើលក្ខខណ្ឌចូលរួមប្រឡងប្រជែង៖</u>

ដើម្បីសម្រួលដល់ការចូលរួមប្រឡងប្រជែង ក្រសួងសូមគូសបញ្ជាក់នូវចំណុចមួយចំនួនស្តីពីសំណុំបែបបទដែលត្រូវបំពេញ ជាពិសេសលើឯកសារដូចខាងក្រោម៖

i. **សេចក្តីចម្លងសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល ៖**
សេចក្តីចម្លងសញ្ញាបត្របរិញ្ញាបត្រជំនាញឯកទេស ឬបរិញ្ញាបត្រលើឯកទេសប្រហាក់ប្រហែល ឬសញ្ញាបត្រសមមូល ឬសញ្ញាបត្របណ្តោះអាសន្ន ឬលិខិតបញ្ជាក់ការបញ្ចប់ការសិក្សាប្រកបដោយជោគជ័យនូវថ្នាក់បរិញ្ញាបត្រ ឬថ្នាក់សញ្ញាបត្រសមមូល ត្រូវមានការបញ្ជាក់សេចក្តីចម្លងត្រឹមត្រូវតាមច្បាប់ដើម ចេញដោយសាលារាជធានី ខេត្ត ឬដោយគណៈកម្មាធិការ ./



អគារលេខ៤៨ មហាវិថីសម្តេចព្រះសីហនុ ទន្លេបាសាក់ ចំការមន ភ្នំពេញ ទូរស័ព្ទ: ០២៣ ២១៣ ៩០៨, ០២៣ ២២០ ៣៦៩ ទូរសារ: ០២៣ ២១២ ៥៤០

វាយតម្លៃកម្រិតសញ្ញាបត្រ។ បេក្ខជន បេក្ខនារី ត្រូវបង្ហាញច្បាប់ដើមនៃសញ្ញាបត្របរិញ្ញាបត្រ ឬច្បាប់ដើមនៃឯកសារបញ្ជាក់ការបញ្ចប់ការសិក្សារបស់ខ្លួនដូចរៀបរាប់ខាងលើ ជូននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្សដើម្បីធ្វើការផ្ទៀងផ្ទាត់បន្ថែម ពេលដាក់ពាក្យសុំចូលរួមប្រឡង។

ii. **ចំពោះ លិខិតបញ្ជាក់ទីលំនៅបច្ចុប្បន្ន លិខិតបញ្ជាក់ទីលំនៅបច្ចុប្បន្ន (សេចក្តីចម្លងប័ណ្ណគ្រួសារ) និង សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត** បេក្ខជន បេក្ខនារីត្រូវប្រគល់ជូនបន្ទាប់ពីប្រឡងជាប់ជាស្ថាពរលើវិញ្ញាសាសរសេរ និងវិញ្ញាសាផ្ទាល់មាត់។

## ២. **កាលបរិច្ឆេទ និងពេលវេលាប្រឡង ៖**

- វិញ្ញាសាសរសេរ៖ ត្រូវបានលើកទៅថ្ងៃសុក្រ **ទី០១ ខែសីហា ឆ្នាំ២០១៤**
  **ព្រឹក៖** ពីម៉ោង ០៩:០០ នាទី ដល់ម៉ោង ១១:០០ នាទី សម្រាប់វិញ្ញាសាចំណេះដឹងទូទៅ
  **រសៀល៖** ពីម៉ោង ១៤:០០ នាទី ដល់ម៉ោង ១៦:០០ នាទី សម្រាប់វិញ្ញាសាជំនាញឯកទេស
- កាលបរិច្ឆេទនៃការប្រកាសលទ្ធផលវិញ្ញាសាសរសេរ និងវិញ្ញាសាផ្ទាល់មាត់ នឹងជូនដំណឹងនៅពេលក្រោយ។

## ៣. **កាលបរិច្ឆេទឈប់ទទួលពាក្យ ៖**

ការទទួលពាក្យសុំចូលរួមប្រឡងប្រជែង នឹងត្រូវបញ្ឈប់ត្រឹម**រសៀលថ្ងៃសុក្រ ទី២៥ ខែកក្កដា ឆ្នាំ ២០១៤ វេលាម៉ោង ១៧:០០ នាទីគត់ជាកំហិត។**

**បញ្ជាក់** ៖ ពាក្យសុំចុះឈ្មោះប្រឡងចូលបម្រើការងារជាមន្ត្រីរាជការក្របខណ្ឌក្រសួងបរិស្ថាន សម្រាប់ឆ្នាំ២០១៤ អាចទាញយកបាននៅគេហទំព័រ៖ www.moe.gov.kh ។

## ៤. **មណ្ឌលប្រឡង ៖**

ការប្រឡងប្រជែងលើវិញ្ញាសាសរសេរ និងវិញ្ញាសាផ្ទាល់មាត់ នឹងប្រព្រឹត្តទៅនៅ**រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ** ដែលមានអាសយដ្ឋាននៅ៖ **អគារលេខ១៧ ផ្លូវ៤៦៦ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។**

## ៥. វិញ្ញាសាប្រឡង ៖

### ៥.១. វិញ្ញាសាសរសេរ ៖

ក. **វិញ្ញាសាចំណេះដឹងទូទៅ** (រយៈពេល ០២ ម៉ោង) ដែលផ្តោតជាអាទិ៍ លើទិដ្ឋភាពប្រវត្តិសាស្ត្រ ភូមិសាស្ត្រ វប្បធម៌អរិយធម៌ និងនយោបាយនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់បេក្ខជន បេក្ខនារីគ្រប់រូប និងគ្រប់ជំនាញឯកទេស។

ខ. **វិញ្ញាសាជំនាញឯកទេស៖**

1) **វិញ្ញាសារដ្ឋបាលទូទៅ នីតិសាស្ត្រ វិទ្យាសាស្ត្រនយោបាយ** សម្រាប់បេក្ខជន បេក្ខនារីដែលមានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលលើជំនាញឯកទេស ឬជំនាញប្រហាក់ប្រហែលដូចតទៅ៖ នីតិសាស្ត្រ រដ្ឋបាលសាធារណៈ នីតិឯកជន នីតិសាធារណៈ ទំនាក់ទំនងអន្តរជាតិ វិទ្យាសាស្ត្រនយោបាយ ទស្សនវិទ្យា អក្សរសាស្ត្រ សង្គមវិទ្យា ប្រវត្តិសាស្ត្រ អក្សរសាស្ត្រភាសាបរទេស និងវិទ្យាសាស្ត្រសង្គមផ្សេងទៀត។

2) **វិញ្ញាសាគណនេយ្យ ហិរញ្ញវត្ថុ និងគ្រប់គ្រង** សម្រាប់បេក្ខជន បេក្ខនារីដែលមានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលលើជំនាញឯកទេស ឬជំនាញប្រហាក់ប្រហែលដូចតទៅ៖ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ គណនេយ្យ ទេសចរណ៍ ពាណិជ្ជកម្ម គ្រប់គ្រង និងវិនិយោគ។

3) **វិញ្ញាសាបរិស្ថាន និងវិទ្យាសាស្ត្រពាក់ព័ន្ធ (ជាអាទិ៍ គីមីវិទ្យា ជីវវិទ្យា គណិតវិទ្យា បរិស្ថាន អេកូឡូស៊ី និងបម្រែបម្រួលអាកាសធាតុ)** សម្រាប់បេក្ខជន បេក្ខនារីដែលមានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលលើជំនាញឯកទេស ឬជំនាញប្រហាក់ប្រហែលដូចតទៅ៖ បរិស្ថាន វិស្វកម្មបរិស្ថាន កសិកម្ម រុក្ខកម្ម វារីវប្បកម្ម គីមី ជីវវិទ្យា រូបវិទ្យា ភូមិវិទ្យា ភូគព្ភសាស្ត្រ គណិតវិទ្យា មាត្រាសាស្ត្រ ផែនទីវិទ្យា ព័ត៌មានវិទ្យា អភិវឌ្ឍន៍ជនបទ បច្ចេកវិជ្ជា វេជ្ជសាស្ត្រ និងឧស្សាហកម្ម។

### ៥.២. វិញ្ញាសាផ្ទាល់មាត់សម្រាប់បេក្ខជន បេក្ខនារី ដែលទទួលបានជោគជ័យនៅដំណាក់កាលវិញ្ញាសាសរសេរ ៖

ក. **វិញ្ញាសាភាសាអង់គ្លេស** (រយៈពេល ៤៥ នាទី ៖ ត្រៀម ១៥ នាទី បទបង្ហាញ ១៥ នាទី និងសំណួរ ចម្លើយ ១៥ នាទី) សម្រាប់បេក្ខជន បេក្ខនារីគ្រប់ជំនាញឯកទេស។

**បញ្ជាក់** ៖ បេក្ខជន បេក្ខនារីត្រូវជួបសម្ភាសន៍ជាមួយនឹងគណៈមេប្រយោគចំនួន ០២ (ពីរ) រូប ដែលនឹងធ្វើការវាយតម្លៃ ប្រកបដោយភាពឯករាជ្យពីគ្នា លើសមត្ថភាពរបស់បេក្ខជន បេក្ខនារី។

ខ. <u>វិញ្ញាសាជំនាញឯកទេស</u> (រយៈពេល ៤៥ នាទី ៖ ត្រៀម ១៥ នាទី បទបង្ហាញ ១០ នាទី និងសំណួរ- ចម្លើយ ២០ នាទី)។

**<u>បញ្ជាក់</u>** ៖ បេក្ខជន បេក្ខនារីត្រូវជួបសម្ភាសន៍ជាមួយនឹងគណៈមេប្រយោគចំនួន ០៣ (បី) រូប ដែលរួមមាន ៖ តំណាងក្រសួងបរិស្ថាន ០១ រូប តំណាងក្រសួងមុខងារសាធារណៈ ០១ រូប និងអ្នកជំនាញឯកទេសលើវិញ្ញាសាជំនាញឯកទេសដូចដែលបានកំណត់ក្នុងដំណាក់កាលវិញ្ញាសាសរសេរខាងលើ។ គណៈមេប្រយោគទាំងបី (០៣) រូប នឹងធ្វើការវាយតម្លៃ ប្រកបដោយភាពឯករាជ្យពីគ្នា លើសមត្ថភាពរបស់បេក្ខជន បេក្ខនារី អនុលោមតាមការយល់ឃើញរៀងៗខ្លួន។

## ៦. ព័ត៌មានបន្ថែម

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងនាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្សនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុរបស់ក្រសួងបរិស្ថាន **ដែលមានទីតាំងស្ថិតនៅអគារលេខ៤៨ មហាវិថីសម្តេចព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ** (តាមបណ្តោយសួនច្បារវិមានឯករាជ្យ) ឬតាមទូរស័ព្ទលេខ **០១១ ៨៤៨ ២៤៥ ឬ ០៩៧ ៦៦៩០០៥៣**។

អាស្រ័យហេតុនេះ សូមនិស្សិត និងសាធារណៈជនទាំងអស់ជ្រាបជាព័ត៌មាន។

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

**កន្លែងទទួល** :

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត
- គ្រប់អង្គភាពចំណុះក្រសួងបរិស្ថាន
- ឯកសារ កាលប្បវត្តិ